ព្រះរាជាណាចក្រកម្ពុជា -ឡ/-

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៩៤

ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០២

សាលដីកា

លេខ : ៥៥

ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣

ក្នុងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅ :-

១ - ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២ - លោក ជីវ កេង ជាចៅក្រមរបាយការណ៍

៣ - លោក ស៊ិន ឌឹម ជាចៅក្រម

៤ - លោក សោម សិរីវឌ្ឍ ជាចៅក្រម

៥ - លោក ម៉ុង មុន្នីចរិយា ជាចៅក្រម

ក្រឡាបញ្ជី

លោក ម៉ៅ សុវណ្ណ

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៧៩ "ឈ" ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៨១៥ ចុះថ្ងៃទី ១៧.១២.២០០១ របស់សាលាឧទ្ធរណ៍ ។

- រវាងដើមចោទ : ១- ចៅ សុខទៀង "ជាចុងបណ្តឹងសាទុក្ខ" ភេទ ស្រី
២- ចៅ សុខណាង "ជាចុងបណ្តឹងសាទុក្ខ" ភេទ ស្រី
៣- ចៅ សុខរីណ "ជាចុងបណ្តឹងសាទុក្ខ" ភេទ ស្រី

តំណាងសិទ្ធិអោយ អ្នកស្រី ចៅ សុខពេង អាយុ ៣៥ ឆ្នាំ ជាតិ ខ្មែរ មុខរបរ:នៅផ្ទះ ទីលំនៅផ្ទះលេខ ៩៩អា០ ផ្លូវ ១៤៦ សង្កាត់ផ្សារដេប៉ូ ២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

- និងចុងចម្លើយ : ១- ចៅ សុខឡាក់ "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទ ស្រី អាយុ ៣០ឆ្នាំ ជាតិ ខ្មែរ មុខរបរ:លក់ដូរ ទីលំនៅផ្ទះលេខ ១៥៦ ផ្លូវលេខ ២១៧ សង្កាត់អូរឬស្សីទី ៣ ខណ្ឌ ៧មករា ក្រុងភ្នំពេញ ។

២- ចៅ សុខលី "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទ ស្រី អាយុ ៣៩ ឆ្នាំ ជាតិ ខ្មែរ ទីលំនៅផ្ទះលេខ ៣៩អា០ ផ្លូវ១៦៤ សង្កាត់អូរឬស្សីទី ៣ ខណ្ឌ ៧មករា ក្រុងភ្នំពេញ ។

កម្មវត្ថុ : ប្តឹងសុំចែកមរតក

តាមបណ្ដឹងសាទុក្ខលេខ ១៧៤ ចុះថ្ងៃទី ១៥.៥.២០០២ របស់អ្នកស្រីជោ សុខឡាក់ និង ជោ សុខលី ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៧៩" ឃ" ចុះថ្ងៃទី០៩.៥.២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៩៤ ចុះថ្ងៃទី ០១.៧.២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ២៧.៣.២០០០ របស់អ្នកស្រី ជោ សុខហេង ជាតំណាងអោយបងប្អូន ០៣នាក់ ដោយមានអ្នកស្រី ជោ សុខឡេង , អ្នកស្រី ជោ សុខលាង , និង អ្នកស្រី ជោ សុខណៃ ប្ដឹងសុំបែងចែកទ្រព្យសម្បត្តិមរតករបស់ម្ដាយខ្លួនឈ្មោះ ចាន់ ញឹប ដែលបានបន្សល់ទុកក្រោយពេលគាត់ស្លាប់មាន :

១_ ផ្ទះលេខ ៣៩អឺ០ ផ្លូវលេខ ១៦៤ សង្កាត់អូឬស្សីទី ៣ ខ័ណ្ឌ ៧មករា ។

២_ ផ្ទះលេខ ១៥៦អឺ០ ផ្លូវលេខ ២១៧ សង្កាត់អូឬស្សីទី៣ ខ័ណ្ឌ៧មករា ។

ដោយសំអាងហេតុថា នៅពេលដែលម្ដាយខ្លួនឈ្មោះ ចាន់ ញឹប បានស្លាប់ទៅ គាត់បានបន្សល់ទុកនូវទ្រព្យសម្បត្តិជាច្រើន ។ ប៉ុន្តែលុះថ្ងៃនេះមើលឃើញជាក់ស្ដែងនៅតែមានផ្ទះចំនួន ០២ល្វែង ដែលមានខាងលើប៉ុណ្ណោះ ដែលត្រូវបងស្រីឈ្មោះ ជោ សុខលី កាន់កាប់ផ្ដាច់មុខនូវផ្ទះល្វែងលេខ ៣៩អឺ០ ផ្លូវលេខ ១៦៤ សង្កាត់អូឬស្សីទី ៣ ខ័ណ្ឌ៧មករា ដែលត្រូវប្អូនឈ្មោះ ជោ សុខឡាក់ កាន់កាប់ផ្ដាច់មុខទៀត ។ នៅថ្ងៃទី១.៤.៩៩ ខ្លួនបានដាក់ពាក្យបណ្ដឹង ០១ច្បាប់ ជំរាបទៅលោកនាយកមន្ទីរសុរិយោដីរាជធានីភ្នំពេញ សុំជួយរាំងស្កាត់ការលក់ដូរផ្ទេរកម្មសិទ្ធិផ្ទះល្វែងទាំងនេះ ដើម្បីរង់ចាំឈ្មោះ ជោ សុខលី និង ឈ្មោះអ្នកទាំងពីរនេះពុំបានចែងចែកអោយត្រឹមត្រូវទេ គឺមានគំនិតលោភលន់ចង់បានចំណែកច្រើនតែឯង ដោយបានចែងចែកអោយបងប្អូន ០៤នាក់ទៀតតែចំនួន ៧.០០០ដុល្លាអាមេរិកប៉ុណ្ណោះក្នុងម្នាក់ៗ ហើយមិនមែនប្រគល់អោយភ្លាមទេ ប្រាក់នេះគឺទាល់តែយូរឆ្នាំទើបប្រគល់រំលោះទៀត ។ ផ្ទះល្វែងទាំងពីរនេះ មានតំលៃមិនតិចទេ អាចពី ២០ទៅ២៨ម៉ឺនដុល្លា តាមតំលៃជាក់ស្ដែង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៣" ៨" ចុះថ្ងៃទី២០.៩.២០០១ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :_

១_ ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ២៧.៣.២០០០ របស់ដើមចោទទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែត្រូវបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២_ ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ២៣.៥.២០០០របស់ដើមចោទឈ្មោះជោ សុខហេង ផ្ទេរសិទ្ធិទៅអោយលោកមេធាវី ទូច ឆេងតិច ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣_ ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ០៩.៥.២០០០ រវាងឈ្មោះជោ សុខឡាក់ និង មេធាវីលោក ជីវ សាន ទុកជាត្រឹមត្រូវតាមច្បាប់ ។

-----៣ ------

៤_ ទទួលស្គាល់កិច្ចសន្យាចែកផ្ទះចុះថ្ងៃទី ០៨.១០.៩៣ របស់ឈ្មោះ ចាន់ ញឹប ចែកអោយកូនឈ្មោះដោ សុខលាង ទុកជាត្រឹមត្រូវតាមច្បាប់ ។

៥_ ប្រគល់ផ្ទះលេខ ១៥៦អ៊ី០ ផ្លូវ ២១៧ សង្កាត់អូរឬស្សី៣ ខ័ណ្ឌ ៧មករា ក្រុងភ្នំពេញ អោយទៅឈ្មោះ ដោ សុខឡាក់ ភេទ ស្រី អាយុ ៣០ឆ្នាំ គ្រប់គ្រងជាកម្មសិទ្ធិស្របច្បាប់ ដោយគិតចាប់តាំងពីសាលក្រមចូលជាស្ថាពរ ។

៦_ ប្រគល់ផ្ទះលេខ ៣៩អ៊ី០ ផ្លូវ ១៦៤ សង្កាត់អូរឬស្សី៣ ខ័ណ្ឌ ៧មករា ក្រុងភ្នំពេញ អោយទៅឈ្មោះ ដោ សុខលី ភេទ ស្រី អាយុ ៣៩ ឆ្នាំ គ្រប់គ្រងជាកម្មសិទ្ធិស្របច្បាប់ ដោយគិតចាប់តាំងពីសាលក្រមចូលជាស្ថាពរតទៅ ។

៧_ រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ៧.០០០រៀល ដែលដើមចោទបានបង់ទុកជាមុនហើយនោះ ប្រាក់នេះត្រូវបង់ចូលពន្ធហ្លួង និង ពន្ធចុះបញ្ជីក្តីចំនួន ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ទីបប្រាក់ចំនួន ២០០រៀល ហើយនិងប្រាក់សំរាប់ស៊ើបអង្កេតចំនួន ៥.០០០រៀល ។ កាលបើរួចបណ្តឹងឧទ្ធរណ៍ បង្គាប់អោយដើមចោទរួមគ្នាបង់ពន្ធសមាមាត្រមួយភាគរយលើតំលៃផ្ទះលេខ១៥៦អ៊ី០ និងផ្ទះលេខ ៣៩អ៊ី០ ហើយប្រាក់នេះត្រូវបង់ចូលក្នុងថវិការដ្ឋចំនួន ៨០ភាគរយ និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន ២០ភាគរយ ។

៨_ សាលក្រមនេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី ៣០.៨.២០០១ ហើយប្រកាសចំពោះគូភាគីនៅថ្ងៃទី ២០.៩.២០០១ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣៦ "ជ" ចុះថ្ងៃទី ២៨.៩.២០០១ របស់ដោ សុខហេង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៣ "ជ" ចុះថ្ងៃទី ២០.៩.២០០១ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៧៩ "ឈ" ចុះថ្ងៃទី ០៩.៥.២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :_

១_ ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៨.៩.២០០១ របស់ឈ្មោះដោ សុខហេង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២_ បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ១៣ "ជ" ចុះថ្ងៃទី ២០.៩.២០០១ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៣_ ផ្ទះលេខ ១៥៦អ៊ី០ ផ្លូវលេខ ២១៧ សង្កាត់អូរឬស្សីទី ៣ ខ័ណ្ឌ ៧មករា ក្រុងភ្នំពេញ , ផ្ទះលេខ ៣៩អ៊ី០ និង ៣៩អ៊ី១ ផ្លូវលេខ ១៦៤ សង្កាត់អូរឬស្សីទី ៣ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ និង ប្រាក់ចំនួន ៤.៩០០ដុល្លាអាមេរិក "បួនពាន់ប្រាំបួនរយដុល្លាអាមេរិក" ដែលជាប្រាក់ថ្លៃលក់ផ្ទះលេខ ៣៩អ៊ី២ ផ្លូវលេខ ១៦៤ សង្កាត់អូរឬស្សីទី ៣ ក្រុងភ្នំពេញ ដែលស្ថិតនៅលើ

ឈ្មោះ ងៅ សុខលាង ត្រូវធ្វើការបែងចែកជា ៦ ចំណែក " ប្រាំមួយចំណែក " ស្មើៗគ្នា ដូចប្រគល់អោយដល់ភាគីម្នាក់ៗ មួយចំណែក ចាប់ពីពេលដែលសាលដីកានេះចូលជាស្ថាពរ ។ក្នុងការបែងចែកនេះ ភាគីណាមួយអាចនឹងចេញប្រាក់ទិញយកផ្ទះដែលត្រូវបែងចែកនេះជាកម្មសិទ្ធិរបស់ខ្លួនបានតាមតំលៃឯកភាពគ្នា ដូចយកប្រាក់នោះមកធ្វើការបែងចែកគ្នា ។ បើពុំមានការឯកភាពគ្នាទេ ត្រូវលក់ទ្រព្យទាំងផ្ទះខាងលើនេះយកប្រាក់មកបែងចែកគ្នា ។

៤_ ការយកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលដើមចោទបានបង់រួចហើយ គឺពន្ធចុះបញ្ជីក្ដី និង ពន្ធប្ដឹងចំនួន ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០រៀល រង្វាន់អ្នកប្រគល់ដីកាកោះចំនួន ៥.០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការចំនួន ៥.០០០រៀល ។ កាលបើផុតបណ្ដឹងសាទុក្ខ បង្គាប់អោយចុងចម្លើយសងប្រាក់ ១៣.០០០រៀល នេះទៅដើមចោទវិញ និង បង្គាប់អោយបង់ពន្ធសមាមាត្រមួយភាគរយលើប្រាក់សរុបដែលត្រូវបែងចែកក្នុងចំណុចទី ៣ ។ ប្រាក់ពន្ធសមាមាត្រនេះដាក់ចូលថវិការដ្ឋ ៨០ភាគរយ និង ត្រូវបានរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

៥_ សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ និង មេធាវីតំណាងអោយចុងចម្លើយឈ្មោះ ងៅ សុខឡាក់ កំបាំងមុខចុងចម្លើយឈ្មោះងៅ សុខលី ។ បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ១៧៤ ចុះថ្ងៃទី ១៥.៥.២០០២ របស់អ្នកស្រីងៅ សុខឡាក់ និង ងៅ សុខលី ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៧៩ " ឃ " ចុះថ្ងៃទី ០៩.៥.២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី ៣០.៧.២០០២របស់អ្នកស្រី ងៅ សុខឡាក់ ។
- បានឃើញសារណាតបចុះថ្ងៃទី ១៣.១១.២០០២ របស់អ្នកស្រី ងៅ សុខហេង ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីកាសាលាឧទ្ធរណ៍លេខ ៧៩ " ឃ " ចុះថ្ងៃទី ០៩.៥.០២ ដែលបានសំរេចសេចក្ដីមកនេះ ត្រឹមត្រូវខ្លះ ខុសខ្លះ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្ដាប់ចម្លើយរបស់អ្នកស្រី ងៅ សុខឡាក់ ជាចុងចម្លើយ និងជាម្ចាស់បណ្ដឹងសាទុក្ខ បានឆ្លើយនៅពេលសវនាការថា : ខ្លួនសុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ព្រោះសាលាឧទ្ធរណ៍កាត់ក្ដីដោយអយុត្តិធម៌ ។ ម្ដាយខ្លួនចែកមរតកអោយបងប្អូនអស់ហើយ ហើយបានផ្ដាំទុកផ្ទះនេះអោយខ្លួនៗ គាត់មិនបានធ្វើជាលាយលក្ខអក្សរទេ គាត់បានផ្ដាំនឹងដីជូនខ្លួន ព្រោះខ្លួនជាកូនពៅ ហើយបងៗ ក៏បាននឹងគ្រប់គ្នាហើយដែរ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី ចៅ សុខពេង តំណាងអោយដើមចោទ និង ជាចុងបណ្តឹងសាទុក្ខ បានឆ្លើយនៅពេលសវនាការថា ៖ ខ្លួនសុំទាមទារបែងចែកផ្ទះលេខ ១៥៦ , ៣៩អ៊ី០ , ៣៩អ៊ី១ , និង ៣៩អ៊ី២ ។ ម្តាយខ្លួនស្លាប់អាយុ ៥០ឆ្នាំជាង គាត់មិនបានចែកផ្ទះអោយ ចៅ សុខឡាក់ ទេ ហើយ ចៅ សុខឡាក់ ក៏មិនបានយកចិត្តទុកដាក់មើលថែរក្សាគាត់ដែរ ។ ខ្លួនសុំបដិសេធចម្លើយយាយ ទៀង ព្រោះគាត់មើលមិនឃើញទេ ។ ម្តាយខ្លួនឈឺមួយយប់ក៏ស្លាប់ ដោយគាត់លេបថ្នាំពុល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់អ្នកស្រី ចៅ សុខឡាក់ និងអ្នកស្រីចៅ សុខពេង តំណាងអោយដើមចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ ១៧៤ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០២ របស់អ្នកស្រី ចៅ សុខលី និង អ្នកស្រី ចៅ សុខឡាក់ ធ្វើទៀងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថាផ្ទះទំនាស់លេខ ៣៩អ៊ី០ ផ្លូវ ១៦៤ សង្កាត់អូរឬស្សីទី ៣ ខ័ណ្ឌ៧មករា ក្រុងភ្នំពេញ ដែលអ្នកស្រី ចៅ សុខលី ទាមទារនោះ ពុំមានភស្តុតាងបញ្ជាក់ពីសន្តតិកម្មតាមឆន្ទៈរបស់សពឈ្មោះ ចាន់ ញ៉ិប ថាប្រគល់អោយអ្នកស្រី ចៅ សុខលី ទេ ដូច្នេះត្រូវធ្វើការបែងចែកដល់ទាយាទទាំងអស់នូវផ្ទះទំនាស់នេះតាមសន្តតិកម្មដែលត្រូវធ្វើតាមច្បាប់ ។

- យល់ឃើញថាការដែលសាលាឧទ្ធរណ៍សំរេចយកផ្ទះលេខ ១៥៦អ៊ី០ ផ្លូវ ២១៧ សង្កាត់អូរឬស្សីទី ៣ ខ័ណ្ឌ ៧មករា ក្រុងភ្នំពេញ មកធ្វើការបែងចែកជាមត៌កអោយកូនទាំង៦នាក់ ដោយអាងហេតុថាផ្ទះទំនាស់នេះមានប័ណ្ណសំគាល់សិទ្ធិដាក់ឈ្មោះម្តាយ ចាន់ ញ៉ិប និង ពុំមានភស្តុតាងតាមផ្លូវច្បាប់បញ្ជាក់ថាម្តាយបានប្រគល់អោយអ្នកស្រី ចៅ សុខឡាក់ ដែលត្រូវតែចែកអោយកូនទាំងអស់នោះ ពុំទាន់មានសំអាងគ្រប់គ្រាន់ទេ ពីព្រោះតុលាការពុំទាន់បានពិចារណាលើចំលើយរបស់យាយទៀង និង ឈ្មោះ មាស សារុន ព្រមទាំងស៊ើបអង្កេតរកភស្តុតាងនានាបន្ថែមទៀត ដើម្បីបញ្ជាក់ពីចំលើយរបស់សាក្សីទាំងពីរនាក់នេះទេ ។

- យល់ឃើញថាអ្នកស្រី ចៅ សុខលី បានទទួលលិខិតបង្គាប់អោយធ្វើសារណា ហើយហើយក៏បានទទួលដីកាកោះដែរ ប៉ុន្តែអ្នកស្រីពុំបានធ្វើសារណា និង ពុំបានមកចូលរួមនាសវនាការនេះដែរ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថាសាលដីការដ្ឋប្បវេណីលេខ ៧៩ "ឈ" ចុះថ្ងៃទី០៩ ខែ ឧសភា ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ខ្លះ ខុសខ្លះ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខអ្នកស្រី ង៉ោ សុខឡាក់ និង អ្នកស្រី ង៉ោ សុខហេង

កំបាំងមុខអ្នកស្រី ង៉ោ សុខលី ប៉ុន្តែបានទុកជាចំពោះមុខ

១_ ទទួលបណ្ដឹងសាទុក្ខលេខ ១៧៤ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០២ របស់អ្នកស្រី_ ង៉ោ សុខលី និង អ្នកស្រី ង៉ោ សុខឡាក់ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹងគតិច្បាប់ខ្លះ ។

២_ តម្កល់សាលដីការដ្ឋប្បវេណីលេខ ៧៩"ណ" ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០២របស់ សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែចំណុចទី ៣ ត្រង់" ផ្ទះលេខ១៥៦អឺ០ ផ្លូវ២១៧ សង្កាត់អូរឬស្សីទី៣ ខ័ណ្ឌ ៧មករា ក្រុងភ្នំពេញ " ដែលយកមកបែងចែកដែរនោះត្រូវទុកជាមោឃៈ ។

៣_ បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១៩៤ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០២ របស់ តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីទៀងវិញត្រង់ចំណុច" ផ្ទះលេខ ១៥៦អឺ០ ផ្លូវ២១៧ សង្កាត់អូរឬស្សីទី ៣ ខ័ណ្ឌ មករា ក្រុងភ្នំពេញ ។

៤_ រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ១៩.០០០រៀល ដែលចុងចម្លើយបានបង់គឺ:_

_ ពន្ធចុះបញ្ជីក្ដី និង ពន្ធតឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន_ ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

_ ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល បង្គាប់អោយគូភាគី បង់ពន្ធសមាមាត្រលើចំណែកដែលត្រូវបែងចែក ។

៥_ សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ។